អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០១៣.....អ.ស.ហ..ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមការចាំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



អគារ១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩៩ ៧០០
#168F, Street 598, Sangkat Chrang Chamres 1, Khan Russei Keo, Phnom Penh, Cambodia
Phone: (+855) 23 999 700

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ កំណត់យន្តការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ក្នុងគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពលើការបណ្តុះបណ្តាលគណនេយ្យករជំនាញ នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

**ប្រការ ៣.-**

ត្រូវបានបង្កើត **គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា** ហៅកាត់ថា **"គ.គ.គ.គ."** សម្រាប់គ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុក **ន.គ.ស** | | ប្រធាន |
| ២. | អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | | អនុប្រធានប្រចាំការ |
| ៣. | ប្រធានក្រុមប្រឹក្សា **ជ.គ.ស.ក.** | | សមាជិក |
| ៤. | អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម | ៣ រូប | សមាជិក |
| ៥. | តំណាងធនាគារជាតិនៃកម្ពុជា | ១ រូប | សមាជិក |
| ៦. | តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| ៧. | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | សមាជិក |
| ៨. | តំណាងអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** | ១ រូប | សមាជិក |
| ៩. | តំណាងនិយ័តករមូលបត្រកម្ពុជា | ១ រូប | សមាជិក |
| ១០. | តំណាងនិយ័តករធានារ៉ាប់រងកម្ពុជា | ១ រូប | សមាជិក |
| ១១. | តំណាងនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | ១ រូប | សមាជិក |
| ១២. | តំណាងនិយ័តករបរធនបាលកិច្ច | ១ រូប | សមាជិក |
| ១៣. | តំណាងនិយ័តករសន្តិសុខសង្គម | ១ រូប | សមាជិក |
| ១៤. | តំណាងអគ្គនាយកដ្ឋានពន្ធដារ | ១ រូប | សមាជិក |
| ១៥. | តំណាងអគ្គនាយកដ្ឋានរតនាគារជាតិ | ១ រូប | សមាជិក |
| ១៦. | តំណាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា | ១ រូប | សមាជិក |
| ១៧. | តំណាងបុគ្គលឯករាជ្យក្នុងវិស័យគណនេយ្យនិងសនវកម្ម | ១ រូប | សមាជិក |
| ១៨. | ប្រធានការិយាល័យអភិវឌ្ឍវិជ្ជាជីវៈនៃ **ន.គ.ស.** | សមាជិកនិងជាលេខាធិការ។ | |

សមាសភាពជាតំណាងក្រសួង-ស្ថាប័នដែលត្រូវបានចាត់តំណាងចូលរួមនៅក្នុង **គ.ក.គ.ក.** អាចត្រូវបានកែ-សម្រួលតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ក.គ.ក.** ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់ប្រធាន **គ.ក.គ.ក.** ។

សមាជិករបស់ **គ.ក.គ.ក.** អាចត្រូវបានផ្លាស់ប្តូរករណីសមាជិកនោះបាត់បង់នីតិសម្បទានៅក្នុងស្ថាប័នដែលខ្លួនតំណាង។

**ប្រការ ៤.-**

**គ.ក.គ.ក.** មានមុខងារនិងភារកិច្ច ដូចតទៅ÷

- ពិនិត្យនិងសម្រេចលើក្របខ័ណ្ឌគោលនយោបាយ ផែនការសកម្មភាព និងផែនការថវិកា សម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ពិនិត្យនិងសម្រេចលើការកំណត់និងកែសម្រួលកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ពិនិត្យនិងសម្រេចលើវិធាន គោលការណ៍ បែបបទ និងនីតិវិធីនានាសម្រាប់គ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- រៀបចំនិងសម្រេចលើបទបញ្ជាផ្ទៃក្នុងរបស់ **គ.ក.គ.ក.**
- ពិនិត្យនិងសម្រេចលើការទទួលស្គាល់ស្ថាប័នបណ្តុះបណ្តាល កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ពិនិត្យនិងសម្រេចលើកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត សេចក្តីត្រូវការនៃបទពិសោធន៍ការងារជាក់ស្តែងក្នុងក្របខ័ណ្ឌនៃកម្មវិធីសិក្សានេះ
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ពិនិត្យនិងសម្រេចចុងក្រោយលើលទ្ធផលប្រឡងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ជំរុញការលើកកម្ពស់គណនេយ្យករជំនាញកម្ពុជា
- អនុវត្តភារកិច្ចផ្សេងទៀតតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ។

**ប្រការ ៥.-**

ក្របខ័ណ្ឌគោលនយោបាយនិងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានពិនិត្យ អនុម័ត និងដាក់ឱ្យអនុវត្តដោយក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ ៦.-**

រចនាសម្ព័ន្ធរបស់ **គ.ក.គ.ក.** មានដូចខាងក្រោម÷

- អនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា
- អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង
- អនុគណៈកម្មាធិការទទួលស្គាល់ការអប់រំ និងការបណ្តុះបណ្តាល
- លេខាធិការដ្ឋាន។

អនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា បំពេញមុខងារជាសេនាធិការឱ្យ គ.ក.គ.ក. លើការងារសិក្សាស្រាវជ្រាវនិងអភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត សេចក្តីត្រូវការនៃបទពិសោធន៍ការងារជាក់ស្តែង ព្រមទាំងសិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីសិក្សាបំពេញបន្ថែមផ្សេងទៀត។

អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង បំពេញមុខងារជាសេនាធិការឱ្យ គ.ក.គ.ក. លើការងាររៀបចំនិងគ្រប់គ្រងការប្រឡងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា និងកម្មវិធីសិក្សាបំពេញបន្ថែមផ្សេងទៀត។

អនុគណៈកម្មាធិការទទួលស្គាល់ការអប់រំ និងបណ្តុះបណ្តាល បំពេញមុខងារជាសេនាធិការឱ្យ គ.ក.គ.ក. លើការងារទទួលស្គាល់ការអប់រំនិងការបណ្តុះបណ្តាល ព្រមទាំងការពិនិត្យវាយតម្លៃលើការលើកលែងលើមុខវិជ្ជារបស់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

ការិយាល័យអភិវឌ្ឍវិជ្ជាជីវៈនៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម នៃនិយ័តករគណនេយ្យនិងសវនកម្ម គឺជាលេខាធិការដ្ឋានរបស់ គ.ក.គ.ក. និងបំពេញមុខងារជាសេនាធិការឱ្យ គ.ក.គ.ក. លើការងាររដ្ឋបាលនិងបច្ចេកទេស។

អាណត្តិរបស់សមាជិកអនុគណៈកម្មាធិការនីមួយៗ មានរយៈពេល ៣(បី)ឆ្នាំ។ សមាសភាពរបស់អនុគណៈកម្មាធិការនីមួយៗ អាចត្រូវបានផ្លាស់ប្តូរ មុនអាណត្តិត្រូវបានបញ្ចប់ ឬបន្ត សម្រាប់អាណត្តិរយៈពេល ៣(បី)ឆ្នាំ បន្តបន្ទាប់ទៀត ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ក.គ.ក.។

មុខងារនិងភារកិច្ច និងសមាសភាពនៃអនុគណៈកម្មាធិការខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ក.គ.ក.។

**ប្រការ ៧.-**

អនុប្រធានប្រចាំការ សមាជិក និងទីប្រឹក្សា នៃ គ.ក.គ.ក. ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ដើម្បីធានានិរន្តរភាព នៅពេលប្រធានអវត្តមាន គ.ក.គ.ក. ត្រូវប្រជុំក្រោមការដឹកនាំរបស់អនុប្រធានប្រចាំការ តាមការប្រគល់សិទ្ធិរបស់ប្រធាន។

កិច្ចប្រជុំរបស់ គ.ក.គ.ក. អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ៥០(ហាសិប) ភាគរយនៃសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ក្នុងករណីដែលកិច្ចប្រជុំលើកទីមួយមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុខ្វះក្វ៉ូរ៉ុម ប្រធានអាចកោះអញ្ជើញប្រជុំម្តងទៀតជាលើកទីពីរបាន ក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំលើកទីមួយ។ ការប្រជុំលើកទីពីរនេះមិនតម្រូវឱ្យមានសមាជិកគ្រប់ចំនួនក្វ៉ូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានមិនបានប្រជុំតាមការអញ្ជើញលើកទីមួយប៉ុណ្ណោះ។

សេចក្តីសម្រេចរបស់ គ.ក.គ.ក. អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំលេងជាពីរស្មើគ្នា សម្លេងរបស់ប្រធាននៃកិច្ចប្រជុំមានឧត្តមានុភាព។

**មាត្រា ៨.-**

រាល់កិច្ចប្រជុំរបស់ គ.ក.គ.ក ត្រូវមានកំណត់ហេតុ ។

សេចក្តីសម្រេចរបស់ គ.ក.គ.ក. ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធាននៃកិច្ចប្រជុំនិងលេខាកត់ត្រា។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាន អនុប្រធានប្រចាំការ និងសមាជិកទាំងអស់នៃ គ.ក.គ.ក. ក្នុងរយៈពេល យ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ។

គ.ក.គ.ក. ត្រូវធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពការងារ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ ៩.-**

លាភការរបស់ប្រធាន អនុប្រធានប្រចាំការ និងសមាជិករបស់ **គ.ក.គ.ក.** និងអនុគណៈកម្មាធិការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់ប្រធាន **គ.ក.គ.ក.**។

**ប្រការ ១០.-**

**គ.ក.គ.ក.** ប្រើប្រាស់ថវិការបស់ **ន.គ.ស.** ដើម្បីបំពេញមុខងារនិងភារកិច្ចរបស់ខ្លួនស្របតាមប្រកាសនេះ។

## ជំពូកទី៣
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១១.-**

**គ.ក.គ.ក.** អាចដាក់ចេញវិធានពាក់ព័ន្ធការគ្រប់គ្រង ការអភិវឌ្ឍ បែបបទ និងនីតិវិធី នៃការអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ក្រោយពីទទួលបានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

**ប្រការ ១២.-**

**គ.ក.គ.ក.** អាចមានទីប្រឹក្សាតាមការចាំបាច់ ដែលត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមសំណើរបស់ប្រធាន **គ.ក.គ.ក.**។

**ប្រការ ១៣.-**

**គ.ក.គ.ក.** អាចប្រើប្រាស់ត្រារបស់ **ន.គ.ស.** ដើម្បីដំណើរការការងាររបស់ខ្លួនបាន។

**ប្រការ ១៤.-**

**គ.ក.គ.ក.** មានថវិកាសម្រាប់ចំណាយដែលជាផ្នែកមួយនៃថវិការបស់ **ន.គ.ស.**។

**គ.ក.គ.ក.** មានប្រភពចំណូលពី÷

- កម្រៃចុះឈ្មោះនិងប្រឡង
- ការលក់ឯកសារ
- កម្រៃសុំការលើកលែងមុខវិជ្ជាណាមួយ ឬច្រើន
- កម្រៃសេវាពាក់ព័ន្ធផ្សេងៗ។

**គ.ក.គ.ក.** អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តជាតិ និងពីប្រភពផ្សេងៗទៀត។

**គ.ក.គ.ក.** អាចស្នើសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដើម្បីប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូលខាងលើ សម្រាប់ជាកម្មវត្ថុនៃការអភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា និងការអភិវឌ្ឍស្ថាប័ន **ន.គ.ស.**។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ ១៥.-**

បទប្បញ្ញត្តិនិងវិធានពាក់ព័ន្ធទាំងឡាយណាដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌនៃប្រកាសលេខ ១៣២ សហវ.ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបន្តសុពលភាពអនុវត្ត រហូតដល់មានបទប្បញ្ញត្តិនិងវិធានថ្មីមកជំនួស។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៦.-**

ប្រកាសលេខ១៣២ សហវ.ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយប្រកាសនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧.-**

អគ្គលេខាធិការនៃអគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

***កន្លែងទទួល:***

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាននៃ អ.ស.ហ.
- និយ័តករគណនេយ្យនិងសវនកម្ម
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ